ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

**សាលក្រមព្រហ្មទណ្ឌ**
លេខ **២២(ឌ)/២៥៣**
ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២១
-សំណុំរឿងព្រហ្មទណ្ឌលេខ ១៥០១
ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០
-សំណុំរឿងស៊ើបសួរលេខ ១២៧២
ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០
-សំណុំរឿងជំនុំជម្រះលេខ ១០៨
ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២១

# គាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ០៨ និង៣០នាទីព្រឹក នៅសាលសវនាការលេខ ខ១ ដែលមានសមាសភាព ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សាជំនុំជម្រះ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៥០១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ទិជាតិ** ភេទប្រុស អាយុ៤៣ឆ្នាំ(កើតឆ្នាំ១៩៧៧) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌**មិនចេះអក្សរ** មុខរបរគ្មាន ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ **សុខ**(ស) ម្តាយឈ្មោះ [redacted] ទ្រី(រ) នៅលីវ ទោសពីមុន គ្មាន (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៦១ យខ/ឋ/២០ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាម **មាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ** ។

**-ជនរងគ្រោះឈ្មោះ** [redacted] **សៅ** ភេទប្រុស អាយុ២៤ឆ្នាំ(កើតឆ្នាំ១៩៩៦) សញ្ជាតិខ្មែរ មុខរបរដាំដំណាំ ទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **សេន** ភេទប្រុស អាយុ៦២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរចៅសង្កាត់រងទី២ នគរធំ លំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ។

## អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ឈ្មោះ [redacted] វិជាតិ បានធ្វើសកម្មភាពវាយយកម្ទ្រព្យពីជនរងគ្រោះឈ្មោះ [redacted] **សៅ** ចំក្បាលជាច្រើនដៃ និងបានយកដំបងវាយទៅលើជនរងគ្រោះបន្ថែមទៀត ហើយបានគេចខ្លួនបាត់។ លុះដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង១១ និង៣០នាទី កម្លាំងកងរាជអាវុធហត្ថខេត្តសៀមរាប បានធ្វើការសហការជាមួយកម្លាំងមូលដ្ឋានស្រុកកំរៀង បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **វិជាតិ** បានតែម្តង។



Scanned with CamScanner

-**បានឃើញ** របាយការណ៍សរុបលេខ ០៣១/០២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថ ខេត្តសៀមរាប ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **២៥ អ.យ** ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តសៀមរាប ។

-**បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **១៩៧ ពស.ព្រស/ឌ** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូង ខេត្តសៀមរាប ។

-**បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ **២៦៧ ពស.ព្រជ(ក)** ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **វិជាតិ** ឆ្លើយថាៈ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួន កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ប្រហែល១១ថ្ងៃត្រង់ នៅស្រុកកំរៀង ខេត្តបាត់ដំបង ខណៈពេលខ្លួនកំពុងតែជិះម៉ូតូម្នាក់ឯងដោយគ្មាន គោលដៅទៅណាទេ។ មូលហេតុដែលសមត្ថកិច្ចឃាត់ខ្លួន ដោយចោទប្រកាន់ថាខ្លួនលួចម៉ូតូគេកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ។ កាលពីរយៈពេល៥ថ្ងៃមុនពេលកើតហេតុ ឈ្មោះ [redacted] **សៅ** ជាអ្នកភូមិរស់នៅជិតគ្នា ជាមួយខ្លួន រួមមានគ្នាប្រហែលជា៤ទៅ៥នាក់បានដេញវាយ និងដេញចាប់ខ្លួន ដោយសារតែខ្លួនយកទូរស័ព្ទ របស់ប្អូនជីដូនមួយខ្លួនទៅបញ្ចាំ ហើយខ្លួនប្រាប់ថាខ្លួននឹងទៅលោះយកមកប្រគល់ឱ្យប្អូនជីដូនមួយខ្លួនវិញ រំលងបានរយៈពេលប្រហែលជា៥ថ្ងៃក្រោយមក ខ្លួនបានឃើញឈ្មោះ [redacted] **សៅ** ជិះម៉ូតូមួយ គ្រឿងម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០០៧ ម្នាក់ឯងហើយយកទៅចតទុកនៅមុខផ្ទះ ឈ្មោះ**ស្រីអូន**។ នៅពេលដែលខ្លួនឃើញឈ្មោះ [redacted] **សៅ** ខ្លួនបានរត់ពួន កុំឱ្យវាឃើញដើម្បីចាំវាយវាវិញដោយសារតែខ្លួនខឹងពីថ្ងៃមុនមក ។ បន្ទាប់ពីឈ្មោះ [redacted] **សៅ** ឈប់ម៉ូតូរួចវាក៏ចូលទៅអង្គុយកៅអី នៅមុខផ្ទះ**ស្រីអូន** ហើយខ្លួនក៏ពួននៅក្រោមដើមស្វាយ ហើយពេលនោះដោយឃើញថាមានឱកាសល្អ ខ្លួនបានចូលទៅចាប់ទាញសក់វាហើយទះចំនួន៤ដៃ ហើយប្រាប់ថា ថ្ងៃក្រោយកុំឱ្យធ្វើចឹងទៀត ហើយឈ្មោះ [redacted] **សៅ** ប្រាប់ថាឈប់ហើយ បន្ទាប់មកវាក៏រត់ទៅ ហើយខ្លួនក៏យកម៉ូតូរបស់ឈ្មោះ [redacted] **សៅ** ជិះទៅទុកនៅស្រះ**តាហូ** បំណងយកទុកឱ្យម្ចាស់គេវិញ តែដោយសារប៉ូលិសទូរស័ព្ទចូល ទូរស័ព្ទខ្លួន សួរដេញដោលច្រើនពេក ខ្លួនក៏ជិះម៉ូតូរត់គេចខ្លួនតែម្តងទៅ។ ខ្លួនវាយឈ្មោះ [redacted] **សៅ** មិនបានយកដំបងវាយទេ គឺវាយតែដៃទទេប៉ុណ្ណោះ។ សមត្ថកិច្ចឃាត់ខ្លួនបានដកហូតបានម៉ូតូម៉ាកឌ្រីមជារបស់ឈ្មោះ [redacted] **សៅ** ចំនួន១គ្រឿង, កាបូបដាក់លុយចំនួន១ ទូរស័ព្ទម៉ាកNokia ចុចពិល ចំនួន១គ្រឿង ក្រៅពីនោះពុំមានអ្វី ផ្សេងទៀតទេ ។ ខ្លួនដឹងកំហុសហើយ ដោយសារកាលនោះខ្លួនខឹងខ្លាំងពេក ។

-ជនរងគ្រោះឈ្មោះ [redacted] **សៅ** ឆ្លើយថាៈ នៅប្រហែល១០ថ្ងៃមុនកើតហេតុ ឈ្មោះ **ជាតិ** បានលួចទូរស័ព្ទគេ ហើយខ្លួនបានប្រាប់ម្ចាស់ទូរស័ព្ទឈ្មោះ **ជាតិ** សន្យាលោះយកឱ្យវិញ តែមិនបានលោះពេលម្ចាស់គេឃើញ ឈ្មោះ **ជាតិ** រត់គេច។ ឈ្មោះ **ជាតិ** ខឹងនឹងខ្លួនដែលប្រាប់ម្ចាស់ទូរស័ព្ទ។ នៅវេលាម៉ោងប្រហែល២រសៀល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ខ្លួនបានជិះម៉ូតូ១គ្រឿង ម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០០៧ ពាក់ផ្លាកលេខ សៀមរាប1B-8777 ទៅលេងផ្ទះឈ្មោះ **អ៊ុន** ភេទស្រី មានតូបលក់ចាប់ហួយ នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ខ្លួនអង្គុយមុខតូប មានអ្នកលក់ និងតួយ អត់មានចាប់អារម្មណ៍ ឬឃើញនរណាផ្សេងទេ ពេលនោះឈ្មោះ **ជាតិ** មកពីក្រោយខ្លួន បានចាប់សក់ក្បាលខ្លួនហើយទះកំភ្លៀងខ្លួនសងខាងជាច្រើនដៃ ខ្លួនយកដៃធ្វេងរង ប៉ះជាមួយដៃឈ្មោះ **ជាតិ** បណ្តាលឱ្យថ្លោះ



Scanned with CamScanner

កដៃ ហើយឈ្មោះ [redacted] វិជាតិ បានរកដំបងប្រុងវាយលើខ្លួនទៀត តែខ្លួនបានរត់គេចចេញស្រែកឱ្យគេជួយ ហើយឈ្មោះ [redacted] វិជាតិ បានរត់ទៅយកម៉ូតូខ្លួន ដែលមានកូនសោរជាប់ស្រេច ជិះចេញទៅបាត់ ។ នៅថ្ងៃបន្ទាប់ទី១៤ ខែធ្នូ ឆ្នាំ២០២០ សមត្ថកិច្ចចាប់បានឈ្មោះ ជាតិ ដកហូតម៉ូតូប្រគល់ឱ្យឪពុកខ្លួនវិញ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេន ឆ្លើយថាៈ ខ្លួនជាឪពុកបង្កើតរបស់ឈ្មោះ [redacted] សៅ ភេទប្រុស។ ម៉ូតូ១គ្រឿង ម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០០៧ ពាក់ផ្លាកលេខសៀមរាប 1B-8777 បាត់កាតគ្រី ជារបស់ខ្លួនទិញស៊េរីឆ្នាំ២០០៧ តម្លៃ ១៨០០ដុល្លាអាមេរិក ម៉ូតូនេះ ខ្លួនឱ្យកូនជិះធ្វើការសំណង់រាល់ថ្ងៃ ។ ខ្លួនដឹងពីការបាត់ម៉ូតូ ដោយកូនទូរស័ព្ទប្រាប់ នៅម៉ោង៣រសៀល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ។ ម៉ូតូនេះត្រូវឈ្មោះ ជាតិ ភេទប្រុស វាយកូនរបស់ខ្លួនហើយយកម៉ូតូជិះទៅបាត់ នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ខ្លួនបានប្ដឹងមកប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់នគរធំ ។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ សមត្ថកិច្ចចាប់ខ្លួនបានឈ្មោះ ជាតិ និងដកយកម៉ូតូនៅស្រុកកំរៀង ខេត្តបាត់ដំបង បញ្ជូនមកកងរាជអាវុធហត្ថខេត្តសៀមរាប និងបានប្រគល់ឱ្យខ្លួនវិញ ។ ខ្លួនមិនទាមទារសំណងអ្វីទេ សូមតុលាការសម្រេចតាមច្បាប់ ។

-តាមអំណានពាក្យបណ្ដឹង ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សេន ថាៈ សុំប្ដឹងឈ្មោះ [redacted] វិជាតិ ភេទប្រុស អាយុ៤៣ឆ្នាំ ទីលំនៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ពីបទ **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តកាលពីវេលាម៉ោង ១៤និង៣០នាទី ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ នៅត្រង់ចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។

-តាមអំណានកំណត់ហេតុចាប់យក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ របស់មន្ត្រីនគរបាលយុត្តិធម៌ថាៈ បានចាប់យកវត្ថុតាងមាន ម៉ូតូចំនួន០១គ្រឿង ម៉ាកហុងដា ឌ្រីម ស៊េរីឆ្នាំ២០០៧ លេខតួ លេខម៉ាស៊ីន ៨១៩៦៨៧៦ និងទូរស័ព្ទចំនួន០១គ្រឿង ម៉ាកណូគា ១២៨០ ពណ៌ខ្មៅ ដែលជាប់ពាក់ព័ន្ធករណី **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តវេលាម៉ោង១៤និង៣០នាទី ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ នៅចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ។

-តាមអំណានរបាយការណ៍សរុបលេខ ០៣១/០២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថខេត្តសៀមរាប សន្និដ្ឋានថាៈ យោងតាមការពិនិត្យជាក់ស្ដែងលើរឿងហេតុបទល្មើសជាក់ស្ដែង វត្ថុតាងចាប់យក កំណត់ហេតុទទួលបណ្ដឹងរបស់ឈ្មោះ [redacted] សេន កំណត់ហេតុស្ដាប់ចម្លើយរបស់ឈ្មោះ [redacted] សៅ និងកំណត់ហេតុស្ដាប់ចម្លើយរបស់ឈ្មោះ **ហុន វិជាតិ** បង្ហាញឲ្យឃើញថាឈ្មោះ [redacted] **វិជាតិ** ភេទប្រុស អាយុ៤៣ឆ្នាំ ពិតជាបានប្រព្រឹត្តនូវអំពើ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តកាលពីវេលាម៉ោង ១៤និង៣០នាទី ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ នៅចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ពិតប្រាកដមែន ដោយបានប្រើអំពើហិង្សាវាយ និងទាត់ជាក់ទៅលើជនរងគ្រោះបណ្ដាលដោយមានរបួសថែមទៀតផង ។

## សេចក្ដីសន្និដ្ឋានបួទសុំរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សាសួរដេញដោលរួចមក ឃើញថា ឈ្មោះ [redacted] **វិជាតិ** ជាជនជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ជនជាប់ចោទបានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះ ដើម្បីយកម៉ូតូ។ តាមការពិនិត្យភស្តុតាង និងចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដដែល និងប្ដឹងសុំឲ្យតុលាការផ្ដន្ទាទោសតាមកំណត់ច្បាប់។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីធ្វើការពិភាក្សាសួរដេញដោលរួចមក ឃើញថា កូនក្តីខ្លួនបានសារភាពទទួលស្គាល់អង្គហេតុ និងការចោទប្រកាន់ កូនក្តីខ្លួនជាជនក្រីក្រ កម្រិតវប្បធម៌ទាប គ្មានការពិចារណាឲ្យបានត្រឹមត្រូវ ដូចនេះខ្លួនជាមេធាវីការពារសិទ្ធិ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ។

## សំដីចុងក្រោយជនជាប់ចោទ

សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១/-កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ ត្រង់ចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **វិជាតិ** បានវាយទៅលើឈ្មោះ [redacted] **សៅ** ហើយយកម៉ូតូរបស់ជនរងគ្រោះជិះគេចខ្លួនបាត់ ក្រោយមកត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបាន រួមទាំងវត្ថុតាងម៉ូតូចំនួន០១គ្រឿង ប្រាកដមែន ។

២/-ចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់គ្នាជាមួយ ចម្លើយចំពោះមុខចៅក្រមស៊ើបសួរ, អយ្យការ, មន្ត្រីនគរបាលយុត្តិធម៌ រួមទាំងស៊ីសង្វាក់ផងដែរជាមួយ កំណត់ហេតុពិនិត្យកន្លែងកើតហេតុ, កំណត់ហេតុចាប់យក, របាយការណ៍សរុប និងភស្តុតាងនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឲ្យជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ដូចការបញ្ជូនមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ប្រាកដមែន ។

៣/-ជនជាប់ចោទពុំមានសញ្ញាណណាមួយនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។

៤/-ជនជាប់ចោទបានធ្វើសកម្មភាពដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជារបស់ខ្លួន ដែលនាំឲ្យខូចប្រយោជន៍ដល់ជនរងគ្រោះ ដែលច្បាប់បញ្ញត្តថាជាបទល្មើស និងផ្តន្ទាទោស ។

៥/-អំពើរបស់ជនជាប់ចោទបានប៉ះពាល់ធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិអ្នកដទៃ បូរណភាពរូបរាងកាយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

៦/-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៧/-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វិជាតិ ភេទប្រុស អាយុ៤៣ឆ្នាំ (កើតឆ្នាំ១៩៧៧) សញ្ជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៨/-តាមស្ថានភាពជនជាប់ចោទ, អង្គហេតុ និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ដែលបានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះដោយគំនុំពីមុន ហើយយកម៉ូតូពីរបស់ជនរងគ្រោះជិះគេចខ្លួនបាត់។ ជនជាប់ចោទបានឆ្លើយសារភាពដឹងកំហុសនឹងឈប់ប្រព្រឹត្តបទល្មើសទៀតហើយ និងសុំឲ្យតុលាការបន្ធូរបន្ថយទោស តាមស្ថានភាពបែបនេះ គប្បីតុលាការពិនិត្យពិចារណា សម្រេចផ្តន្ទាទោសលើជនជាប់ចោទនេះ ក្នុងកម្រិតធួនល្មមតាមច្បាប់កំណត់ ។

៩/-ដើមបណ្តឹងរដ្ឋប្បវេណីមិនទាមទារសំណងជំងឺចិត្តអ្វីឡើយ ព្រោះបានទទួលម៉ូតូវិញហើយ គប្បីតុលាការពុំលើកយកមកពិចារណា និងសម្រេចទេ ។

## ហេតុដូច្នេះសម្រេច

-ផ្តន្ទាទោសឈ្មោះ [redacted] **ទិដាតិ** ភេទប្រុស អាយុ៤៣ឆ្នាំ(កើតឆ្នាំ១៩៧៧) សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០៤(បួន)ឆ្នាំ**

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាម**មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ** ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃចន្ទ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប , ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០

បានឃើញ
**ប្រធានក្រុមប្រឹក្សា**

[redacted]

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី.០៧.ខែកក្កដាឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]